# កិច្ចព្រមព្រៀងគម្រោង

* * * * * * *

រវាង

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

ជាមួយនឹង

អង្គការ មេត្រីអន្តរជាតិ

**សង្ខេបគម្រោងកម្មវិធី៖**

- ឈ្មោះគម្រោង៖ ការការពារ ទប់ស្កាត់ សង្គ្រោះ ស្តារ និងការអភិវឌ្ឍន៍
- ឈ្មោះស្ថាប័នអនុវត្តគម្រោង៖ អង្គការ មេត្រីអន្តរជាតិ
- អាសយដ្ឋានរបស់ស្ថាប័នអនុវត្តគម្រោង៖ ស្ថិតនៅដីឡូត៍លេខ ២៧៣០-១៦២០ ផ្លូវ២៨គ្រួសារ ភូមិរោងចក្រ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ ទូរស័ព្ទ៖ ០៨៩ ២២ ៩០ ៤៣/០១២ ៣១៨ ៩៨០/០៨៩ ៩២០ ៨៣៩
អ៊ីម៉ែល៖ aimissions@yahoo.com ឬ info@aim4asia.org ប្រអប់សំបុត្រ៖ ០៥៧១
វែបសាយ៖ www.agapewebsite.org ឬ www.freedommandate.com
- ទីកន្លែងអនុវត្តគម្រោង៖ រាជធានីភ្នំពេញ ខេត្តសៀមរាប និងទទួលយកជនរងគ្រោះពី ២៥ រាជធានី-ខេត្ត
- អាសយដ្ឋានការិយាល័យធំនៅប្រទេសអាម៉េរិក ៖151N. Sunrise Ave., Suite 1006, Roseville, CA 95661 Tel: (916) 7842800
- ថេរៈវេលារបស់គម្រោង៖ ០៣ឆ្នាំ
  - ចាប់ផ្តើម៖.........27 JUL 2017.........
  - បញ្ចប់៖.........27 JUL 2020.........
- **ថវិកាគម្រោងសរុប៖ ៤,៨៣៣,៦៩៦ ដុល្លារអាម៉េរិក**
- អ្នកផ្តល់ថវិកាគាំទ្រគម្រោង៖

| ឈ្មោះស្ថាប័នផ្តល់ថវិកា | ទឹកប្រាក់(ដុល្លារអាម៉េរិក) |
|---|---|
| AGAPE International Mission (USA) | ៤,៨៣៣,៦៩៦ |
| សរុប | ៤,៨៣៣,៦៩៦ |

- គណនីប្រើប្រាស់ថវិកាខាងលើនៅក្នុងប្រទេសកម្ពុជា៖
ធនាគារពាណិជ្ជកម្មក្រៅប្រទេសនៃកម្ពុជា(FTB)ដែលមានលេខគណនី ០១០៣០៤១៣០០០០៦១-៣
- ប្រភពថវិកាដែលបានផ្តល់ខាងលើទាំងនេះ ត្រូវតែជាថវិកាដើម្បីជួយដល់ក្រុមគោលដៅមនុស្សធម៌សុទ្ធសាធ គ្មានការពាក់ព័ន្ធទៅនឹងកិច្ចការយោធា នយោបាយ ឬសាសនាឡើយ។
- ចំនួនបុគ្គលិកបរទេស៖ ១១នាក់ (ស្រី ០៦នាក់)
- ចំនួនបុគ្គលិកខ្មែរ៖ ១៦៧នាក់ (ស្រី ១៣២ នាក់)

**គោលដៅកិច្ចសហប្រតិបត្តិការៈ**

- ជួយទប់ស្កាត់ និងសង្គ្រោះជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងការរំលោភបំពានផ្លូវភេទ
- ផ្តល់កន្លែងស្នាក់នៅដែលមានសុវត្ថិភាពស្របតាមបទដ្ឋានអប្បបរមាសម្រាប់ការថែទាំជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ដែលស្នាក់នៅក្នុងមជ្ឈមណ្ឌល ដោយស្តារនីតិសម្បទាជនរងគ្រោះបែបចិត្តសាស្ត្រ អារម្មណ៍ បញ្ញាស្មារតី ផ្តល់ម្ហូបអាហារ សំលៀកបំពាក់ សម្ភារៈប្រើប្រាស់ ការសិក្សាអប់រំ និងការថែទាំសុខភាព
- ធ្វើសមាហរណកម្មជនរងគ្រោះដែលបានស្តារនីតិសម្បទា និងបន្តជួយពង្រឹងសមត្ថភាពរៀនជំនាញកាត់ដេរ ធ្វើសក់ផាត់មុខ ចាក់ខ្សែដៃ និងបោះពុម្ពលើអាវ... ។ល។

## ពណ៌នាគម្រោងកម្មវិធី

គម្រោងនេះបង្កើតឡើងក្រោយពីពិនិត្យឃើញថា ការជួញដូរមនុស្ស និងការរំលោភបំពានផ្លូវភេទ នៅតែជាបញ្ហាប្រឈម តម្រូវឲ្យមានការចូលរួមសហការពីអង្គការជាមួយរាជរដ្ឋាភិបាលកម្ពុជា ក្នុងការជួញសង្គ្រោះ ស្តារនិងអភិវឌ្ឍជនរងគ្រោះ។

**<u>គម្រោងនេះអនុវត្តៈ</u>**

- រាជធានីភ្នំពេញៈ ដីឡូត៍លេខ ២៧៣០-១៦២០ ផ្លូវ ២៨គ្រួសារ ភូមិរោងចក្រ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ ទូរស័ព្ទៈ ០៨៩ ២២ ៩០ ៤៣/០៩៧ ៦៩៧ ៩៦៣៣/ ០១២ ៣១៨ ៩៨០/០៨៩ ៩២០ ៨៣៩
  អ៊ីម៉ែលៈ aimissions@yahoo.com ឬ info@aim4asia.org ប្រអប់សំបុត្រៈ ០៥៧១
- ខេត្តសៀមរាបៈ ផ្ទះលេខ ១A និង ២A ផ្លូវ Top Town ភូមិសាលាកន្សែង សង្កាត់ស្វាយដង្គំ ក្រុងសៀមរាប ខេត្តសៀមរាប នឹងមានវិសាលភាពគ្របដណ្តប់ នៅតាមបណ្តាខេត្តផ្សេងៗទៀត។

ផលប្រយោជន៍ដែលទទួលបានពីគម្រោងនេះរួមមានៈ

ក. កម្មវិធីនៅភ្នំពេញ

- <u>មជ្ឈមណ្ឌលមេត្រីលើកស្ទួយនៃក្តីស្រឡាញ់ (ARC)</u> ផ្តល់កន្លែងថែរក្សាបន្ថែមទៀតដល់ជនរងគ្រោះ និងងាយរងគ្រោះនៃការកេងប្រវ័ញ្ចផ្លូវភេទ និងការរំលោភសេពសន្ថវៈ និងបំពេញសេចក្តីត្រូវការដល់ពួកគាត់ នូវសុខសុវត្ថិភាពរាងកាយ ផ្លូវចិត្ត សង្គម និងការអប់រំ ។
- <u>ផ្ទះរ៉ាហាប់ភ្នំពេញ(RHPP)</u>
  ផ្តល់កន្លែងសំចត និងកន្លែងថែរក្សាបន្ថែមទៀតដល់ជនរងគ្រោះ និងងាយរងគ្រោះនៃការកេងប្រវ័ញ្ចផ្លូវភេទ និងការរំលោភផ្លូវភេទ និងបំពេញសេចក្តីត្រូវការដល់ពួកគាត់នូវ សុខសុវត្ថិភាព រាងកាយ ផ្លូវចិត្ត សង្គម និងការអប់រំ ។
- <u>ផ្ទះសង្គ្រោះបឋមសម្រាប់កុមារ (EFC)</u>
  ផ្តល់កន្លែងស្នាក់រយៈពេលខ្លីសម្រាប់កុមារដែលរងគ្រោះ និងងាយរងគ្រោះដោយអំពើជួញដូរ ឬកុមារដែលត្រូវបានក្រុមគ្រួសារទុកចោល ។ លើសពីនេះទៀតយើងក៏ស្តារឡើងវិញនូវការបង្រួបបង្រួមក្រុមគ្រួសារវិញសំពួកគាត់ផងដែរ ។
- <u>ក្លឹបកីឡាហាត់ប្រាណក្នុងសហគមន៍ (LG)</u>
  ផ្តល់ជាក្លឹបហាត់ប្រាណ និងគ្រូបង្វឹក ដោយមិនគិតថ្លៃដល់ជនរងគ្រោះ និងងាយរងគ្រោះដោយអំពើជួញដូរមនុស្ស និងការកេងប្រវ័ញ្ចផ្លូវភេទ ហើយវាក៏ជាកន្លែងផ្តល់នូវជម្រើសមួយឆ្ពោះទៅរកអាជីពជាអ្នកប្រដាល់ ។

- **កម្មវិធីបណ្តុះបណ្តាលជំនាញ ទី១ ( ATP)**

  ផ្តល់បំណិនជីវិតនៃវិជ្ជាជីវៈ និងឱកាសការងារដល់ជនរងគ្រោះ និងងាយរងគ្រោះដែលត្រូវបានគេកេងប្រវ័ញ្ចផ្លូវភេទ និងការរំលោភបំពានផ្លូវភេទ ។

- **កម្មវិធីបណ្តុះបណ្តាលជំនាញ ទី២ ( ATP)**

- ផ្តល់បំណិនជីវិតនៃវិជ្ជាជីវៈ និងឱកាសការងារដល់ជនរងគ្រោះ និងងាយរងគ្រោះដែលស្ថិតក្នុងហានិភ័យនៃការកេងប្រវ័ញ្ចផ្លូវភេទ និងការរំលោភបំពានផ្លូវភេទ ។

**ខ. កម្មវិធីនៅខេត្តសៀមរាប**

- **ផ្ទះរ៉ាហាប់សៀមរាប (RHSR)**

  ផ្តល់កន្លែងសំចត និងកន្លែងថែរក្សាបន្ថែមទៀតដល់ជនរងគ្រោះ និងងាយរងគ្រោះនៃការកេងប្រវ័ញ្ចផ្លូវភេទ និងការរំលោភបំពានផ្លូវភេទ និងបំពេញនូវសេចក្តីត្រូវការ សុខសុវត្ថិភាព រាងកាយ ផ្លូវចិត្ត សង្គម និងការអប់រំដល់ពួកគេ ។ ចូលរួមសហការជាមួយមន្ត្រីជំនាញដែលមានសមត្ថកិច្ច ក្នុងការត្រួតពិនិត្យកន្លែងដែលអាចកើតមានការកេងប្រវ័ញ្ចផ្លូវភេទ ដូចជា ក្លឹបកំសាន្ត ខារ៉ាអូខេ ហាងម៉ាស្សា។

- **កម្មវិធីបណ្តុះបណ្តាលជំនាញ ទី៣ ( ATP)**

- ផ្តល់នូវបំណិនជីវិតនៃវិជ្ជាជីវៈ និងឱកាសការងារដល់ជនរងគ្រោះ និងងាយរងគ្រោះដែលត្រូវបានគេកេងប្រវ័ញ្ចផ្លូវភេទ និងការរំលោភបំពានផ្លូវភេទ ។

- **ផ្ទះនាងរ៉ាហាប់កុមារផ្កាឈូក ( RHLKC)**

  ផ្តល់ឲ្យកុមារ និងក្រុមគ្រួសារកុមាររងគ្រោះ និងងាយរងគ្រោះនូវការសង្គ្រោះបឋម ជំនួយមនុស្សធម៌ កម្មវិធីសិក្សាអប់រំ ក្លឹបកុមារ ចំណេះដឹងទូទៅ សិល្បៈ និងវិជ្ជាជីវៈ ។

**គ/ ការផ្តល់ជម្រកស្នាក់នៅក្រោយវិបត្តិៈ**

- ការការពារ ទប់ស្កាត់ សង្គ្រោះ ស្តារ ការអភិវឌ្ឍ និងការថែទាំក្រោយពីវិបត្តិដោយផ្តល់ឲ្យកន្លែងស្នាក់នៅក្នុងមជ្ឈមណ្ឌលដែលមានសុខសុវត្ថិភាព ជំនួយផ្នែកច្បាប់ ម្ហូបអាហារ សម្លៀកបំពាក់ ការព្យាបាលសុខភាពរាងកាយ និងផ្លូវចិត្តតាមរយៈការពិគ្រោះយោបល់ ការអប់រំ បំណិនជីវិត និងការអភិវឌ្ឍ
- យើងបាននឹងកំពុងថែទាំជនរងគ្រោះ ចំនួន៧២នាក់ (៥៦នាក់ នៅភ្នំពេញ និង១៦នាក់ នៅសៀមរាប ហើយមានលទ្ធភាពអាចពង្រីកបន្ថែម ប្រសិនបើមានជនរងគ្រោះ) និងកុមាររងគ្រោះនិងងាយរងគ្រោះដោយសារការជួញដូរ និងកេងប្រវ័ញ្ចផ្លូវភេទ ចំនួន២០នាក់ ប្រុស៥នាក់ ស្រី១៥នាក់។

**ឃ.សមាហរណកម្មទៅសហគមន៍វិញៈ**

- ធ្វើសមាហរណកម្មជនរងគ្រោះទៅសហគមន៍វិញ បន្ទាប់ពីពួកគាត់បានទទួលការស្តារនីតិសម្បទា បានជាសះស្បើយ និងមានសុវត្ថិភាពពេញលេញ
- បន្តជួយពង្រឹងសមត្ថភាពលើជំនាញកាត់ដេរ ធ្វើសក់ ផាត់មុខ ចាក់ខ្សែដៃ និង បោះពុម្ពលើសម្លៀកបំពាក់ ។ល។ ដើម្បីឲ្យពួកគាត់មានលទ្ធភាពអាចរកការងារធ្វើ។ ទន្ទឹមនោះយើងបានឧបត្ថម្ភដល់ជនដែលបានស្តារនីតិសម្បទារួចចំនួន១៧៥នាក់ ដោយផ្តល់ប្រាក់ខែ អាហារថ្ងៃត្រង់មួយពេល ការពិនិត្យសុខភាព និងការពិគ្រោះយោបល់។

ក្រុមគោលដៅដែលទទួលបានសេវាខាងលើជាផ្លែផ្កានៃកិច្ចសហប្រតិបត្តិការរវាងអង្គការ និងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។

តារាងចំនួនក្រុមគោលដៅប៉ាន់ប្រមាណទទួលបានផលប្រយោជន៍ពីគម្រោង៖

| ល.រ | ក្រុមគោលដៅ និងទីតាំង | ចំនួន | | | ផ្សេង |
|---|---|---|---|---|---|
| | | ស្រី | ប្រុស | សរុប | |
| រាជធានីភ្នំពេញ | | | | | |
| ១ | ជនរងគ្រោះស្នាក់នៅ | ១៩០ | ៤០ | ២៣០ | |
| ២ | ជនរងគ្រោះបានសមាហរណកម្ម នៅទទួលសេវាអង្គការ | ១១០ | ១០ | ១២០ | |
| ខេត្តសៀមរាប | | | | | |
| ១ | ជនរងគ្រោះទទួលការស្នាក់នៅ | ១៥០ | ៤០ | ១៩០ | |
| ២ | ជនរងគ្រោះបានសមាហរណកម្ម នៅទទួលសេវាអង្គការ | ៥៦ | ៣០ | ៨៦ | |
| សរុបការស្នាក់នៅ | | ៣៤០ | ៨០ | ៤២០ | |
| សរុបការធ្វើសមាហរណកម្ម | | ១៦៦ | ៤០ | ២០៦ | |

**លក្ខខណ្ឌលម្អិត**

**ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា**

**និង**

**អង្គការមេត្រីអន្តរជាតិ**

**បានព្រមព្រៀងដូចខាងក្រោមនេះ**

## មាត្រា ១

## លក្ខខណ្ឌទូទៅនៃកិច្ចព្រមព្រៀង

១.១ កិច្ចព្រមព្រៀងនេះគឺធ្វើឡើងក្រោមកិច្ចសហប្រតិបត្តិការរវាង **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា** និង **អង្គការមេត្រីអន្តរជាតិ** ដើម្បីអនុវត្ត និងវាយតម្លៃលើសកម្មភាពទាំងមូលរបស់គម្រោងឱ្យស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា។

១.២ រាល់ការអនុវត្តកម្មវិធីត្រូវបានពិភាក្សាជាមួយមន្ទីរជំនាញថ្នាក់រាជធានី ខេត្តដែលមានការពាក់ព័ន្ធ។

១.៣ រាល់ការសាងសង់សំណង់ណាមួយ ត្រូវធ្វើការពិភាក្សាល្អិតល្អន់ជាមួយ **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** ជាមុនសិនទើបអាចដំណើរការបាន។ ប្លង់សាងសង់រួមទាំងក្បាច់រចនា ត្រូវធ្វើឡើងស្របតាមបទដ្ឋានជាតិ ។

១.៤ កាលបរិច្ឆេទនៃគម្រោងចាប់ផ្តើមនៅថ្ងៃទី.................................................................................
និងបញ្ចប់ទៅវិញថ្ងៃទី.............................................................................................

១.៥ ក្នុងភាពជាដៃគូការងារ **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** និង **អង្គការ មេត្រីអន្តរជាតិ** បានឯកភាពគ្នាថា នឹងធ្វើការពិនិត្យឡើងវិញលើគម្រោងនេះយ៉ាងតិច ០៣ខែ មុនកាលបរិច្ឆេទបញ្ចប់នៃគម្រោង។ ក្រោយពីបានពិនិត្យនិងពិភាក្សាគ្នារួចហើយ សេចក្តីសម្រេចរួមគ្នានឹងត្រូវធ្វើឡើង ថាតើត្រូវបញ្ចប់គម្រោងតាមពេលកំណត់ ឬស្វែងរកកិច្ចបន្តគម្រោងនេះមួយរយៈបន្ថែមទៀត។

១.៦ កិច្ចព្រមព្រៀងនេះត្រូវបានប្រើប្រាស់ជាផ្លូវការដោយ **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** និង **អង្គការមេត្រីអន្តរជាតិ** សម្រាប់ជាមូលដ្ឋានក្នុងការធ្វើសហប្រតិបត្តិការ

១.៧ អង្គការត្រូវគោរពតាមច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ដែលបានអនុម័តឲ្យប្រើប្រាស់នៅថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៥។

## មាត្រា ២
## អង្គការមេត្រីអន្តរជាតិ បានព្រមព្រៀងៈ

២.១ អនុវត្តការងារដើម្បីសម្រេចនូវទិសដៅរបស់គម្រោងជាក់លាក់ដូចខាងក្រោមៈ

- ផ្តល់នូវការថែទាំតាមបែបចិត្តសាស្ត្រ អារម្មណ៍ និងការថែទាំដោយបញ្ញាស្មារតីសម្រាប់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស រឺដោយការធ្វើអាជីវកម្មលើផ្លូវភេទ
- ធ្វើសមាហរណកម្មពួកគេត្រឡប់ទៅសហគមន៍វិញ ប្រកបដោយសុវត្ថិភាព និងជួយឧបត្ថម្ភជាចំណូលប្រចាំខែ ។

២.២ សហការយ៉ាងជិតស្និទ្ធជាមួយ **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** ដែលជាដៃគូការងារ ដើម្បីទទួលបានលទ្ធផលកម្រិតអតិបរមាក្នុងការផ្ទេរនិងពង្រឹងជំនាញបច្ចេកទេស

២.៣ រាល់ការបោះពុម្ព ឯកសារទាំងឡាយណាដែលបានពីសមិទ្ធផលរបស់គម្រោងនេះត្រូវដាក់ជូនក្រសួងផ្តល់យោបល់រួច ហើយនឹងត្រូវចាត់ទុកជាសម្បត្តិរួមគ្នារបស់ **អង្គការមេត្រីអន្តរជាតិ** និង **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** ។

២.៤ ចូលរួមឱ្យបានទៀងទាត់រាល់កិច្ចប្រជុំនីមួយៗតាមការអញ្ជើញរបស់ **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវ-នីតិសម្បទា** ដើម្បីសម្របសម្រួលសកម្មភាពរបស់គម្រោងដែលកំពុងដំណើរការ ព្រមទាំងធ្វើការផ្លាស់ប្តូរព័ត៌មានគ្នាដើម្បីឈានទៅសម្រេចជោគជ័យតាមទិសដៅរបស់គម្រោង។

២.៥ ផ្តល់របាយការណ៍ប្រចាំត្រីមាស ឆមាស ៩ខែ និងប្រចាំឆ្នាំ (តាមគំរូរបាយការណ៍របស់នាយកដ្ឋានជំនាញ) ជូនក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា របាយការណ៍ដូចគ្នានេះត្រូវចម្លងជូនៈ

- នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងសមាហរណកម្មជនរងគ្រោះ
- មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រាជធានីភ្នំពេញ និងខេត្តសៀមរាប ដែលអង្គការធ្វើសកម្មភាព។

២.៦ ក្នុងរយៈពេល០១ឆ្នាំ បន្ទាប់ពីក្រសួងនិងអង្គការបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងជាផ្លូវការរួចមកបើ **អង្គការ មេត្រីអន្តរជាតិ** ពុំបានធ្វើរបាយការណ៍ដូចមានចែងនៅក្នុងមាត្រា ២.៥ ក្រសួងកំណត់ថា **អង្គការ មេត្រីអន្តរជាតិ** ពុំបានអនុវត្តគម្រោងកម្មវិធីហើយត្រូវចាត់ទុកជាមោឃៈ និងអស់សុពលភាពដោយស្វ័យប្រវត្តិ។

២.៧ ទទួល ឬបង្គលក្ខណៈដល់មន្ត្រីរបស់ **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** រាជធានី ខេត្ត ដើម្បីធ្វើការក្នុងគម្រោងកម្មវិធីដោយយោងលើប្រភេទនៃគម្រោងកម្មវិធីដូចជាមធ្យោបាយធ្វើដំណើរ កិច្ចសម្របសម្រួលទំនាក់ទំនងការងារ។

២.៨ ជូនដំណឹងមក **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** ជាលាយលក្ខណ៍អក្សរនៅពេលដែលអង្គការផ្លាស់ប្តូរអាសយដ្ឋាន ប្រធានអង្គការ ឬគម្រោងកម្មវិធី លេខទូរស័ព្ទ និងទូសារទំនាក់ទំនង។ ចំពោះករណីមានការនាំចូលឧបករណ៍ និងសម្ភារដែលយកមកប្រើប្រាស់គាំទ្រឲ្យសកម្មភាពគម្រោង អង្គការត្រូវជូនដំណឹងមក **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** តាមពេលវេលាសមស្របមុនពេលដែលឧបករណ៍សម្ភារៈគ្រោងនាំចូលនោះមកដល់ទឹកដីនៃព្រះរាជាណាចក្រកម្ពុជា។

២.៩ គម្រោងថវិកាដែលបានអនុម័ត ត្រូវប្រើប្រាស់ឱ្យមានប្រសិទ្ធភាពតាមទិសដៅដូចបានកំណត់ (ចំណាយរដ្ឋបាលដោយមិនផ្ទាល់មិនត្រូវលើស ២៥% នៃចំណាយសរុប)។

## គម្រោងចំណាយថវិកាសរុបរួម

| គម្រោងចំណាយ | ២០១៧-១៨ | ២០១៨-១៩ | ២០១៩-២០ | ទឹកប្រាក់សរុប |
|---|---|---|---|---|
| ចំណាយលើការជួលការិយាល័យ | ៧៣,០០៨.០០ | ៧៤,០៥៨.០០ | ៧៥,១១១.០០ | ២២២,១៧៧.០០ |
| ចំណាយលើប្រាក់ខែបុគ្គលិកបរទេស | ៣៦,៤៨០,០០ | ៣៨,៣០៤.០០ | ៤០,២១៩.០០ | ១១៥,០០៣.០០ |
| ចំណាយសម្រាប់ការិយាល័យ និងការងាររដ្ឋបាល | ១០,៧២០.០០ | ១១,២២៤.០០ | ១១,៧៥៣.០០ | ៣៣,៦៩៧.០០ |
| **សរុបចំណាយមិនផ្ទាល់** | ១២០.២០៨.០០ | ១២៣,៥៨៦.០០ | ១២៧,០៨៣.០០ | ៣៧០,៨៧៧.០០ |
| ចំណាយលើប្រាក់ខែបុគ្គលិកខ្មែរធ្វើការ សម្រាប់គម្រោងផ្ទាល់ | ១៩១,៧៥៨.០០ | ២០០,៧២៨.០០ | ២១០,១៤៧.០០ | ៦០២,៦៣៣.០០ |
| ចំណាយលើការជួលផ្ទះសំរាប់ជនរងគ្រោះស្នាក់នៅ | ១៨៧,៦១៦.០០ | ១៨៥,៥០២.០០ | ១៨៩,០៦១.០០ | ៥៦២,១៧៩.០០ |
| ចំណាយលើការបណ្តុះបណ្តាលជំនាញ | ១៣៤,៣៩៨.០០ | ១៣៤,៦៦២.០០ | ១៣៤,៩៣៩.០០ | ៤០៣,៩៩៩.០០ |
| ចំណាយលើសិក្ខាសាលា | ៦១,២០០.០០ | ៦១,២៨៧.០០ | ៦១,៣៧៩.០០ | ១៨៣,៨៦៦.០០ |
| ចំណាយលើការផ្គត់ផ្គង់សម្ភារនិងបរិក្ខារ | ២៥,០៨០.០០ | ២៦,៣៣៤.០០ | ២៧,៦៤៩.០០ | ៧៩,០៦៣.០០ |
| មធ្យោបាយដឹកជញ្ជូន និងធ្វើដំណើរ | ៩៨,០៨៨.០០ | ១០០,០២០.០០ | ១០២,០៤៨.០០ | ៣០០,១៥៦.០០ |
| ចំណាយលើការជួសជុល ឡាន ម៉ូតូកង់បី ម៉ូតូ និងផ្ទះ | ១៦,៥៨៦.០០ | ១៧,៤១៥.០០ | ១៨,២៨៦.០០ | ៥២,២៨៧.០០ |
| ចំណាយលើជំនួយបន្ទាន់ ឬជានាវ៉ាប់រង | ៩៩,២៨៨.០០ | ១០១,២៨០.០០ | ១០៣,៣៧១.០០ | ៣០៣,៩៣៩.០០ |
| ចំណាយលើម្ហូបអាហារ សំលៀកបំពាក់ និងសម្ភារសំរាប់ក្រុមគោលដៅ | ១៩២,៦៩៧.០០ | ១៧៨,៦២២.០០ | ១៨១,០៩៦.០០ | ៥៥២,៤១៥.០០ |
| ចំណាយលើថ្លៃសិក្សា សម្ភារសិក្សា និងថែទាំសុខភាព ដល់ក្រុមគោលដៅ | ២៥៥,៣៨៤.០០ | ២៦១,៦៥៦.០០ | ២៦៨,២៨២.០០ | ៧៨៥,៣២២.០០ |
| ចំណាយតាមលើអតិថិជនដែលបានសមាហរណកម្ម និងក្រុមគ្រួសារ | ២០៧,៦៥៣.០០ | ២០៧,៦៥៣.០០ | ២០៧,៦៥៤.០០ | ៦២២,៩៦០.០០ |
| ចំណាយលើការចូលរួមចំណែកការងារជាមួយរដ្ឋាភិបាល | ៤,០០០.០០ | ៤,៧០០.០០ | ៥,៣០០.០០ | ១៤,០០០.០០ |
| **សរុបចំណាយផ្ទាល់** | ១,៤៧៣,៧៤៨.០០ | ១,៤៧៥,១៥៩.០០ | ១,៥០៩,[illegible].០០ | ៤,៥[illegible]១៩.០០ |
| **ចំណាយសរុបគម្រោងរួម** | ១,៥៨២,៣៣៣,០០ | ១,៦០៩,២៥៥.០០ | ១,៦៤២,៦០៨.០០ | [illegible],៨[illegible]៣,៦៩៦.០០ |

4873.696 16

២.១០ ជំនួយរបស់ **អង្គការ មេត្រីអន្តរជាតិ** ជាជំនួយសម្រាប់ឧបត្ថម្ភចំពោះជនរងគ្រោះពីការជួញដូរ និងការ រំលោភបំពានធ្ងន់ធ្ងរ ជាកម្មវិធីមនុស្សធម៌សុទ្ធសាធ ហើយអង្គការនេះនឹងមិនប្រើប្រាស់ជំនួយនេះក្នុងគោលបំណងនយោបាយ សាសនា ឬយោធា ឡើយ។

២.១១ គោរពតាមច្បាប់ អនុក្រឹត្យ គោលនយោបាយ ប្រកាស និងលិខិតបទដ្ឋានគតិយុទ្ធពាក់ព័ន្ធជាអាទិ៍៖

- ច្បាប់ស្តីពីសមាគមនិងអង្គការមិនមែនរដ្ឋាភិបាលចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៥
- អនុក្រឹត្យស្តីពីការគ្រប់គ្រងមណ្ឌលថែទាំកុមារលេខ ១១៩.អនក្រ.បក ចុះថ្ងៃទី ១១ ខែកញ្ញា ឆ្នាំ ២០១៥
- អនុក្រឹត្យលេខ ៩០ អនក្រ.បក ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ ២០១៥ ស្តីពីការកែសម្រួលមាត្រាទី៧ នៃអនុក្រិត្យលេខ ១១៦ អនក្រ.បក ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ ២០០៦ ស្តីពីរបបគោលនយោបាយចំពោះជនរងគ្រោះស្នាក់នៅក្នុងមជ្ឈមណ្ឌលរបស់រដ្ឋ
- ការថែទាំជំនួសចំពោះកុមារមានទម្រង់គ្រប់គ្រងករណីចំនួន ២៨ទម្រង់
- ប្រកាសលេខ ១៣៣/១២ ប្រ-ក ចុះថ្ងៃទី ២៥ ខែធ្នូ ឆ្នាំ២០១៥ ស្តីពីការដាក់ឲ្យអនុវត្តគោលការណ៍ណែនាំ ស្តីពីបែបបទនិងនីតិវិធីការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្សដើម្បីផ្តល់សេវាសមស្រប
- ប្រកាសលេខ ២១៧៨ ស.អ.យ ចុះថ្ងៃទី ២០ ខែសីហា ឆ្នាំ ២០១៥ ស្តីពីការដាក់ឲ្យប្រើប្រាស់អនុវត្តឧបករណ៍ត្រួតពិនិត្យនិងវាយតម្លៃការអនុវត្តគោលនយោបាយ និងបទដ្ឋានអប្បបរមា ស្តីពីកិច្ចការពារសិទ្ធិជនរងគ្រោះដោយអំពើជួញដូរមនុស្ស
- ប្រកាសលេខ ១២៧៤ ស.អ.យ ចុះថ្ងៃទី ១៩ ខែឧសភា ឆ្នាំ ២០១៤ ស្តីពីបទដ្ឋានអប្បបរមាសម្រាប់ការថែទាំជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទដែលស្នាក់នៅក្នុងមជ្ឈមណ្ឌល
- នីតិវិធីប្រតិបត្តិការបទដ្ឋានស្តីពីការផ្តល់លើការគាំទ្រផ្នែកសមាហរណកម្មដល់ជនរងគ្រោះដែលជាបុរសដោយអំពើជួញដូរមនុស្ស ខែឧសភា ឆ្នាំ២០១២
- ប្រកាសលេខ ៨៥២ ស.អ.យ ចុះថ្ងៃទី ៣១ ខែសីហា ឆ្នាំ ២០០៩ ស្តីពីការដាក់ឲ្យអនុវត្តគោលនយោបាយស្តីអំពីកិច្ចការពារសិទ្ធិជនរងគ្រោះដោយអំពើជួញដូរមនុស្ស
- ប្រកាសលេខ ៨៥៧ ស.អ.យ ចុះថ្ងៃទី ០៣ ខែកញ្ញា ឆ្នាំ ២០០៩ ស្តីពីបទដ្ឋានអប្បបរមាសម្រាប់កិច្ចការពារសិទ្ធិជនរងគ្រោះដោយអំពើជួញដូរមនុស្ស
- សារាចរណែនាំលេខ ០០៩ ស.អ.យ ចុះថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០០៧ ស្តីពីការងារសមាហរណកម្ម និងតាមដានក្រុមជនរងគ្រោះដែលបានស្នាក់នៅក្នុងមណ្ឌលរបស់រដ្ឋ និងអង្គការមិនមែនរដ្ឋាភិបាល
- ឯកសារណែនាំស្តីពីនីតិវិធីប្រគល់ និងទទួលជនរងគ្រោះដោយសារការជួញដូរមនុស្ស រវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណៈរដ្ឋសង្គមនិយមវៀតណាមឆ្នាំ២០១០។

២.១២ អនុញ្ញាតឲ្យមន្ត្រី **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** ចុះត្រួតពិនិត្យ វាយតម្លៃ និងតាមដានគម្រោងកម្មវិធីរបស់អង្គការ។

២.១៣ ផ្តល់ច្បាប់ថតចម្លងកិច្ចព្រមព្រៀងនេះ ទៅនាយកដ្ឋានជំនាញ និង **មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** រាជធានី ខេត្តពាក់ព័ន្ធ ដែលអង្គការធ្វើសកម្មភាព ក្រោយពីកិច្ចព្រមព្រៀងនេះចូលជាធរមាន។

## មាត្រា ៣

## ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ព្រមព្រៀង៖

៣.១ ចាត់តាំងបុគ្គលិកដែលមានលក្ខណៈសម្បត្តិ និងសមត្ថភាពសមស្រប (ថ្នាក់ក្រសួង មន្ទីរ ការិយាល័យ ក្រុង-ស្រុក-ខណ្ឌ) ឲ្យបំពេញការងារជាមួយ **អង្គការមេត្រីអន្តរជាតិ** ដើម្បីឲ្យសកម្មភាពគម្រោងអនុវត្តទៅមានប្រសិទ្ធភាព និងទាន់ពេលវេលា។

៣.២ អនុញ្ញាតឲ្យ **អង្គការមេត្រីអន្តរជាតិ** អាចជួលបុគ្គលិកធ្វើការបាន ដោយអនុលោមតាមច្បាប់របស់ព្រះរាជាណាចក្រកម្ពុជា។

៣.៣ សម្របសម្រួលក្នុងករណីចាំបាច់ដល់ការសុំទិដ្ឋាការឲ្យបុគ្គលិក និងទីប្រឹក្សាអង្គការដែលចូលរួមក្នុងសកម្មភាពគម្រោង និងទទួលស្គាល់តាមលក្ខខណ្ឌនៃកិច្ចព្រមព្រៀងនេះ។

៣.៤ សម្របសម្រួលតាមករណីសមស្របដើម្បីស្នើសុំពន្ធ និងអាករ ជាបន្ទុករបស់រាជរដ្ឋាភិបាលកម្ពុជា ដល់ឧបករណ៍ និងសម្ភារៈដែលយកមកប្រើប្រាស់គាំទ្រឲ្យសកម្មភាពគម្រោង។

៣.៥ ជំរុញឲ្យមន្ទីរជំនាញរាជធានី-ខេត្ត ឬ ក្រុង-ស្រុក-ខណ្ឌ ធ្វើការប្រាស្រ័យទាក់ទងឲ្យបានជិតស្និទ្ធិជាមួយអង្គការ ដើម្បីជួយកសាងផែនការគ្រប់គ្រង និងដោះស្រាយបញ្ហា។

៣.៦ រាល់សំណើផ្សេងៗពីអង្គការ នឹងត្រូវបានផ្តល់ចម្លើយពីក្រសួងវិញជាលាយលក្ខណ៍អក្សរ។

៣.៧ អនុញ្ញាត **អង្គការមេត្រីអន្តរជាតិ** ពិភាក្សាជាមួយនាយកដ្ឋានជំនាញ ឬអង្គភាពជំនាញពាក់ព័ន្ធរបស់ **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា** លើកិច្ចដំណើរការដើម្បីសម្រេចបាននូវការព្រមព្រៀងផ្សេងៗ ស្របតាមលិខិតបទដ្ឋានគតិយុត្តរបស់ក្រសួងរួចស្នើសុំសេចក្តីសម្រេចពីរដ្ឋមន្ត្រី **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា**។

## មាត្រា ៤
## លក្ខខណ្ឌរួម

៤.១ **អង្គការមេត្រីអន្តរជាតិ** ត្រូវជ្រើសតាំងជាតំណាងស្របច្បាប់ដោយ **អង្គការមេត្រីអន្តរជាតិសហរដ្ឋអាម៉េរិក** នឹងត្រូវផ្តល់សិទ្ធិ ដល់តំណាងអង្គការនេះដើម្បីធ្វើការជាមួយ **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** ។

៤.២ វិសោធនកម្មជាលាយលក្ខណ៍អក្សរនៃកិច្ចព្រមព្រៀងនេះ អាចធ្វើទៅបានដោយមានការព្រមព្រៀងគ្នាទៅវិញទៅមក និងចុះហត្ថលេខាដោយភាគីទាំងពីរបន្ទាប់ពីបានពិចារណារួចហើយ។

៤.៣ កិច្ចព្រមព្រៀងនេះ អាចត្រូវបានបញ្ចប់ក្នុងស្ថានភាពបន្ទាន់តាមការសម្រេចមួយ រវាងតំណាង **អង្គការមេត្រី អន្តរជាតិ** និង **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** ក្រោយពីបានពិគ្រោះ និងពិចារណារួចរាល់ហើយ។

៤.៤ **អង្គការមេត្រីអន្តរជាតិ** មានសិទ្ធិបញ្ឈប់សកម្មភាពភ្លាមលើកិច្ចព្រមព្រៀងនេះ ក្រោយពីបានពិភាក្សាជាមួយ **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** ប្រសិនជាពិនិត្យឃើញថាគ្មាន កិច្ចសហប្រតិបត្តិការគ្រប់គ្រាន់សម្រាប់ការអនុវត្តគម្រោងឱ្យមានប្រសិទ្ធភាព ឬសន្តិសុខនៃបុគ្គលិក ឬទ្រព្យសម្បត្តិរបស់ខ្លួនស្ថិតក្នុងប្រជានស័ក្ត។

៤.៥ **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** មានសិទ្ធិបញ្ចប់កិច្ចព្រមព្រៀងនេះ ដោយចេញលិខិតរបស់ក្រសួងជាផ្លូវការ ប្រសិនបើការអនុវត្តដំណោះស្រាយដូចក្នុងមាត្រា ៤.២ ៤.៣ និង ៤.៤ នៃកិច្ចព្រមព្រៀងនេះមិនអាចសម្រេចបាន ឬមានគោលការណ៍ថ្មីតម្រូវ ។

៤.៦ បន្ទាប់ពីបានពិភាក្សាជាមួយ **អង្គការមេត្រីអន្តរជាតិ** រួច **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** នឹងស្នើសុំឱ្យអង្គការ បញ្ឈប់ការងារចំពោះបុគ្គលិកណាដែលត្រូវបានវិនិច្ឆ័យថា ធ្វើឱ្យខូចកិត្តិយសក្រសួង ឬបានប្រព្រឹត្តខុសនឹងក្រមសីលធម៌វិជ្ជាជីវៈរបស់ខ្លួនហើយ **អង្គការ មេត្រីអន្តរជាតិ** ត្រូវអនុវត្តតាមដំណើរការនេះ។

៤.៧ ក្រោយពីបានពិភាក្សាជាមួយស្ថាប័នពាក់ព័ន្ធ **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** មានសិទ្ធិបញ្ឈប់កិច្ចព្រមព្រៀងនេះ ប្រសិនបើតំណាងផ្លូវការរបស់ **អង្គការមេត្រីអន្តរជាតិ** ត្រូវបានគេវិនិច្ឆ័យឃើញថាមិនបានបំពេញតាមមាត្រា ២ នៃកិច្ចព្រមព្រៀងនេះ។

៤.៨ កិច្ចព្រមព្រៀងនេះអនុញ្ញាតិឲ្យអង្គការបន្តកិច្ចសហប្រតិបត្តិជាមួយ **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** ក្នុងថេរវេលាដូចមានចែងក្នុងមាត្រា ១.៤ ។ ចំពោះការគ្រប់គ្រងជនរងគ្រោះដោយអំពើជួញដូរមនុស្ស អង្គការត្រូវអនុវត្តតាមបទដ្ឋាននានាពាក់ពន្ធ័ការងារជួញដូរមនុស្សដែល **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា**បានផ្សព្វផ្សាយឲ្យអនុវត្តហើយការទទួលខុសត្រូវស្ថិតនៅក្នុងដែនសមត្ថកិច្ចរបស់នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងសមាហរណកម្មជនរងគ្រោះរបស់ **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា**ដូចនេះតម្រូវឲ្យអង្គការត្រូវបំពេញបែបបទនិងលក្ខខណ្ឌនានាដែលមានបញ្ជាក់ពីការកំណត់របស់នាយកដ្ឋានប្រឆាំង ការជួញដូរមនុស្ស និងសមាហរណកម្មជនរងគ្រោះ។

៤.៩ ប្រសិនបើ **អង្គការមេត្រីអន្តរជាតិ** មិនគោរពតាមច្បាប់របស់ព្រះរាជាណាចក្រកម្ពុជា **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** អាចបញ្ឈប់កិច្ចព្រមព្រៀងនេះ បន្ទាប់ពីជូនព័ត៌មានដល់សាមីអង្គការនោះ។

៤.១០ កិច្ចព្រមព្រៀងនេះ មានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខា ហើយមានសុពលភាពរហូតដល់ថ្ងៃបញ្ចប់គម្រោង។
*កិច្ចព្រមព្រៀងនេះ ត្រូវបានរៀបចំឡើងដោយឥតកែប្រែជាភាសាខ្មែរ ។*

បានចុះហត្ថលេខានៅរាជធានីភ្នំពេញ ថ្ងៃទី...........27 JUL 2017...................

**ហត្ថលេខី**

**តំណាងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា**

ឈ្មោះ៖ **ឯកឧត្តម សួង ម៉េងឡុង**

តួនាទី៖ **អគ្គនាយកកិច្ចការរដ្ឋបាល និងហិរញ្ញវត្ថុ**

**តំណាងអង្គការមេត្រីអន្តរជាតិ**

ឈ្មោះ៖ DONALD BREWSTER

តួនាទី៖ **ប្រធានអង្គការ**

## ១. គម្រោងថវិកានៅរាជធានីភ្នំពេញៈ

| គម្រោងចំណាយ | ២០១៧-១៨ | ២០១៨-១៩ | ២០១៩-២០ | ទឹកប្រាក់សរុប |
|---|---|---|---|---|
| ចំណាយលើការជួលការិយាល័យ | ៧២,០០០.០០ | ៧៣,០០០.០០ | ៧៤,០០០.០០ | ២១៩,០០០.០០ |
| ចំណាយលើប្រាក់ខែបុគ្គលិកបរទេស | ២៥,៦៨០.០០ | ២៦,៩៦៤.០០ | ២៨,៣១២.០០ | ៨០,៩៥៦.០០ |
| ចំណាយសម្រាប់ការិយាល័យ និងការងាររដ្ឋបាល | ៥,៥០០.០០ | ៥,៧៧០.០០ | ៦,០៥៣.០០ | ១៧,៣២៣.០០ |
| **សរុបចំណាយមិនផ្ទាល់** | **១០៣,១៨០.០០** | **១០៥,៧៣៤.០០** | **១០៨,៣៦៥.០០** | **៣១៧,២៧៩.០០** |
| ចំណាយលើប្រាក់ខែបុគ្គលិកខ្មែរធ្វើការសម្រាប់គម្រោងផ្ទាល់ | ១,១៥៣,២១០.០០ | ១៦០,៤៥៨.០០ | ១៦៨,០៦៩.០០ | ៤៨១,៧៣៧.០០ |
| ចំណាយលើការជួលផ្ទះសំរាប់ជនរងគ្រោះស្នាក់នៅ | ១១៤,៣០៨.០០ | ១១១,៦៥៦.០០ | ១១៣,៩១០.០០ | ៣៣៩,៨៧៤.០០ |
| ចំណាយលើការបណ្ដុះបណ្ដាលជំនាញ | ៦៩,១៨៨.០០ | ៦៩,៣២០.០០ | ៦៩,៤៥៧.០០ | ២០៧,៩៦៥.០០ |
| ចំណាយលើសិក្ខាសាលា | ៥៩,៦៤៨.០០ | ៥៩,៧០៨.០០ | ៥៩,៧៧១.០០ | ១៧៩,១២៧.០០ |
| ចំណាយលើការផ្គត់ផ្គង់សម្ភារនិងបរិក្ខារ | ២៣,៥២០.០០ | ២៤,៦៩៦.០០ | ២៥,៩៣០.០០ | ៧៤,១៤៦.០០ |
| មធ្យោបាយដឹកជញ្ជូន និងធ្វើដំណើរ | ៩៤,០៨៨.០០ | ៩៥,៨៧០.០០ | ៩៧,៧៤១.០០ | ២៨៧,៦៩៩.០០ |
| ចំណាយលើការជួសជុល ឡាន ម៉ូតូកង់បី ម៉ូតូ និងផ្ទះ | ១៤,៤០០.០០ | ១៥,១២០.០០ | ១៥,៨៧៦.០០ | ៤៥,៣៩៦.០០ |
| ចំណាយលើជំនួយបន្ទាន់ ឬជានាក់ប់រង | ៩៣,៧២៨.០០ | ៩៥,៤៩២.០០ | ៩៧,៣៤៤.០០ | ២៨៦,៥៦៤.០០ |
| ចំណាយលើម្ហូបអាហារ សំលៀកបំពាក់ និងសម្ភារសំរាប់ក្រុមគោលដៅ | ១១៣,៥៨១.០០ | ៩៨,៦៧៨.០០ | ១០០,២៨៣.០០ | ៣១២,៥៤២.០០ |
| ចំណាយលើថ្លៃសិក្សា សម្ភារសិក្សា និងថែទាំសុខភាព ដល់ក្រុមគោលដៅ | ១៧០,២៦៨.០០ | ១៧៥,៤១២.០០ | ១៨០,៨៥៤.០០ | ៥២៦,៥៣៤.០០ |
| ចំណាយតាមលើអតិថិជនដែលបានសមាហរណកម្ម និងក្រុមគ្រួសារ | ២០៧,៦៥៣.០០ | ២០៧,៦៥៣.០០ | ២០៧,៦៥៤.០០ | ៦២២,៩៦០.០០ |
| ចំណាយលើការចូលរួមចំណែកការងារជាមួយរដ្ឋាភិបាល | ៣,០០០.០០ | ៣,៥០០.០០ | ៤,០០០.០០ | ១០,៥០០.០០ |
| **សរុបចំណាយផ្ទាល់** | ២,១១៦,៥៩២.០០ | ១,១១៧,៥៦៣.០០ | ៩៧២,៨២០.០០ | ៣,៣៧៥,០[illegible] |
| **ចំណាយសរុបគម្រោង** | ២,២១៩,៧៧២.០០ | ១,២២៣,២៩៧.០០ | ១,០[illegible] | [illegible] |

## ២. គម្រោងថវិកានៅខេត្តសៀមរាប ៖

| គម្រោងចំណាយ | ២០១៧-១៨ | ២០១៨-១៩ | ២០១៩-២០ | ទឹកប្រាក់សរុប |
|---|---|---|---|---|
| ចំណាយលើការជួលការិយាល័យ | ១,០០៨.00 | ១,០៥៨.00 | ១,១១១.00 | ៣,១៧៧.00 |
| ចំណាយលើប្រាក់ខែបុគ្គលិកខ្មែរ | ១០,៨០០.00 | ១១,៣៤០.00 | ១១,៩០៧.00 | ៣៤,០៤៧.00 |
| ចំណាយសម្រាប់ការិយាល័យ និងការងាររដ្ឋបាល | ៥,២២០.00 | ៥,៤៥៤.00 | ៥,៧០០.00 | ១៦,៣៧៤.00 |
| **សរុបចំណាយមិនផ្ទាល់** | **១៧,០២៨.00** | **១៧,៨៥២.00** | **១៨,៧១៨.00** | **៥៣,៥៩៨.00** |
| ចំណាយលើប្រាក់ខែបុគ្គលិកខ្មែរធ្វើការសម្រាប់គម្រោងផ្ទាល់ | ៣៨,៥៤៨.00 | ៤០,២៧០.00 | ៤២,០៧៨.00 | ១២០,៨៩៦.00 |
| ចំណាយលើការជួលផ្ទះសម្រាប់ជនរងគ្រោះស្នាក់នៅ | ៧៣,៣០៨.00 | ៧៣,៨៤៦.00 | ៧៥,១៥១.00 | ២២២,៣០៥.00 |
| ចំណាយលើការបណ្តុះបណ្តាលជំនាញ | ៦៥,២១០.00 | ៦៥,៣៤២.00 | ៦៥,៤៨២.00 | ១៩៦,០៣៤.00 |
| ចំណាយលើសិក្ខាសាលា | ១,៥៥២.00 | ១,៥៧៩.00 | ១,៦០៨.00 | ៤,៧៣៩.00 |
| ចំណាយលើការផ្គត់ផ្គង់សម្ភារនិងបរិក្ខារ | ១,៥៦០.00 | ១,៦៣៨.00 | ១,៧១៩.00 | ៤,៩១៧.00 |
| មធ្យោបាយដឹកជញ្ជូន និងធ្វើដំណើរ | ៤,០០០.00 | ៤,១៥០.00 | ៤,៣០៧.00 | ១២,៤៥៧.00 |
| ចំណាយលើការជួសជុល ឡាន ម៉ូតូកង់បី ម៉ូតនិងផ្ទះ | ២,១៨៦.00 | ២,២៩៥.00 | ២,៤១០.00 | ៦,៨៩១.00 |
| ចំណាយលើជំនួយបន្ទាន់ ឬជានាវ៉ាប់រង | ៥,៥៦០.00 | ៥,៧៨៨.00 | ៦,០២៧.00 | ១៧,៣៧៥.00 |
| ចំណាយលើម្ហូបអាហារ សំលៀកបំពាក់ និងសម្ភារៈសំរាប់ក្រុមគោលដៅ | ៧៩,១១៦.00 | ៧៩,៩៤៤.00 | ៨០,៨១៣.00 | ២៣៩,៨៧៣.00 |
| ចំណាយលើថ្លៃសិក្សា សំភារៈសិក្សា និងថែទាំសុខភាពដល់ក្រុមគោលដៅ | ៨៥,១១៦.00 | ៨៦,២៤៤.00 | ៨៧,៤២៨.00 | ២៥៨,៧៨៨.00 |
| ចំណាយលើការចូលរួមចំណែកការងារជាមួយរដ្ឋាភិបាល | ១,០០០.00 | ១,២០០.00 | ១,៣០០.00 | ៣,៥០០.00 |
| **សរុបចំណាយផ្ទាល់** | ៣៥៧,១៥៦.00 | ៣៦២,២៩៦.00 | ៣៦៨,៣២៣.00 | ១,០៨៧,៧៧៥.00 |
| **ចំណាយសរុបគម្រោង** | ៣៧៤,១៨៤.00 | ៣៨០,១៤៨.00 | ៣៨៧,០៤១.00 | ១,១៤១,៣៧៣.00 |